# របាយការណ៍ប្រចាំឆមាស

| | | |
|---|---|---|
| ឈ្មោះគ្រោងការ | : | សេវាជួយជនរងគ្រោះដោយសារមីន |
| របាយកាណ៏ជូន | : | ឯកឧត្តម យី វាំសនា នាយកប្រតិបត្តិមជ្ឈមណ្ឌលជាតិជនពិការ |
| របាយកាណ៏ដោយ | : | លោក គាន អូរ៉ អ្នកសំរបសំរួលសហគមន៏ខេត្តបាត់ដំបង |
| រយៈពេល | : | ខែ មករា-មិថុនា-២០០០៩ |

## ១ សកម្មភាពសង្ខេប

-ចូលរួមប្រជុំជាមួយលោកអនុប្រធានមន្ទីរសង្គមកិច្ច

-ចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំនិងមេភូមិក្នុងឃុំជ្រៃ

-ចូលរួមប្រជុំជាមួយការបណ្តុះបណ្តាលនៅTIB

-ចូលរួមប្រជុំជាមួយអង្គការដែលពាក់ព័ន្ធនិងវិស័យពិការភាព

-សកម្មភាពចុះជួយជនពិការ

-ការបង្កើតគណៈកម្មកាណ៏អភិវឌ្ឍន៏ជនពិការឃុំ

-សកម្មភាពចុះតាមដានជនពិការដល់លំនៅដ្ឋាន

## ២ សមិទ្ធិផលនិងជោគជ័យ

-ខ្ញុំបានចូលរួមប្រជុំជាមួយលោកអនុប្រធានមន្ទីរសង្គមកិច្ចដើម្បីបង្ហាញលំអិតពីគំរោងSSLSដែលជាគំរោងថ្មីរបស់ NCDP ដែលមានសកម្មភាពចុះជួយបង្កើតមុខរបរ ផ្តល់សំភារៈនិងជួយសាងសង់ផ្ទះដល់គាត់ជាប្រយោជន៏ដើម្បីអោយគាត់មានជីវភាពសមរម្យនិងកាត់បន្ថយភាពរើងអើងក្នុងសហគមន៏របស់គាត់ ។ ដោយឡែកក្នុងកិច្ចប្រជុំនោះលោកអនុប្រធានមានការចាប់អារម្មណ៏យ៉ាងខ្លាំងក្នុងការធ្វើការសហការជាមួយNCDP ក្នុងនោះដែលលោកបានស្នើសុំអោយរូបខ្ញុំចូលរួមកិច្ចប្រជុំមួយខែម្តងជាមួយនិងអង្គការដែលពាក់ព័ន្ធនិងវិស័យពិការភាពក្នុងខេត្តបាត់ដំបងនិងបានផ្តល់ឈ្មោះមន្ត្រីសង្គមកិច្ចស្រុកដើម្បីសហការជាមួយរូបខ្ញុំ ។

-ខ្ញុំបានចូលរួមកិច្ចប្រជុំជាមួយក្រុមប្រឹក្សាឃុំនិងលោកមេភូមិទាំងអស់ក្នុងឃុំជ្រៃ ក្នុងកិច្ចប្រជុំនោះលោកមេឃុំបានលើកឡើងពីផែនការណ៏អភិវឌ្ឍន៏ឃុំនិងកញ្ចប់ថវិការសំរាប់អភិវឌ្ឍន៏សហគមន៏និងជនពិការ ។ ក្នុងកិច្ចប្រជុំរូបខ្ញុំបានបង្ហាញពី

គំរោងSSLS ជូនដល់អង្គប្រជុំទាំងមូលមានលោកមេឃុំនិងមេភូមិ ។-ខ្ញុំបានចូលរួមការបណ្តុះបណ្តាលនៅTib ដែលមានប្រធានបទដូចខាងក្រោម:

១. របៀបបង្កើតក្រុមជួយខ្លួនឯង

២.វិធីសាស្ត្របោះឆ្នោតរើសគណៈកម្មការណ៍ជនពិការ

-ខ្ញុំបានចូលរួមជាមួយអង្គការដែលពាក់ព័ន្ធនិងវិស័យពិការភាពដែលរៀបចំឡើងដោយអង្គការ HIF នៅមន្ទីរសុខាភិបាលខេត្តក្រោមប្រធានបទការរំលោភផ្លូវភេទលើស្ត្រីពិការ ។ នៅក្នុងកិច្ចប្រជុំអង្គការ HIF បានបង្ហាញអំពីសកម្មភាពរបស់គំរោងទៅកាន់អ្នកចូលរួម ។

## ៣. សកម្មភាពចុះជួយជនពិការ

- ការចុះទៅជួបជនពិការនិងវាយតំលៃ

ក្នុងរយៈពេលពីខែ មករា ដល់ខែមិថុនានេះ **SSLS** ក្រុងបាត់ដំបងបានចុះទៅជួបជនពិការនិងវាយតំលៃទៅលើជនពិការចំនួន ៨នាក់ ក្នុងការសិក្សានិងស្វែងយល់ពីតំរូវការរបស់ពួកគាត់ ។ ដោយផ្អែកតាមការវាយតំលៃពួកគាត់ទាំង៧នាក់ពិតជាជនពិការដែលមានជីវភាពក្រលំបាកពិតប្រាកដមែន ហើយមជ្ឈមណ្ឌលជាតិនៃជនពិការបានជួយពង្រីកមុខរបរ ជួសជុលផ្ទះនិង សាងសង់ផ្ទះជូនគាត់ ។

- កាផ្តល់ទុន និង ជួសជុលផ្ទះជូនជនពិការ:

មជ្ឈមណ្ឌលជាតិនៃជនពិការក្រោមការដឹកនាំរបស់ ឯកឧត្តម យី វាសនា គឺមានការគាំទ្រយ៉ាងខ្លាំងពីសំណាក់ជនពិការ ក្រុមគ្រួសាររបស់ជនពិការ សហគមន៍ និង ប្រជាពលរដ្ឋទូទៅ ។ ជាក់ស្តែង កាលពីថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៩ ឯកឧត្តម យី វាសនា និង សហការីបានចុះទៅជួបបងប្អូនពិការផ្ទាល់នៅសហគមន៍ ហើយក្នុងជំនួបនោះ ឯកឧត្តមបានធ្វើការសំណេះសំណាលជាមួយបងប្អូនពិការដើម្បីសិក្សាស្វែងយល់ពីតំរូវការនិងការខ្វះខាតរបស់គាត់និងការជួសជុល និងសាងសង់ផ្ទះថ្មីជូនពួកគាត់ ។ នៅក្នុងពេលជាមួយនោះដែរ ឯកឧត្តមបានផ្តល់អនុសាសន៏ជាច្រើនដល់បងប្អូនជនពិការអោយមានការអំណត់ អត់ធន់ព្យាយាម និងខំពង្រីកមុខរបរដែលមជ្ឈមណ្ឌលជាតិនៃជនពិការបានផ្តល់ទុនអោយ ។

នៅក្នុងជំនួបនោះ បងប្អូនពិការបានស្នើសុំឯកឧត្តមនាយកសំរាប់បង្កើតមុខរបរនិងសាងសង់ផ្ទះ និង ពូជសំភារៈសំរាប់ធ្វើស្រែចំការ ។ ក្នុងពេលជាមួយគ្នានោះដែរឯកឧត្តមបានយល់ព្រមតាមសំណើររបស់ជនពិការម្នាក់ៗដូចខាងក្រោម:

១.ប្រាក់ សុខឿន ភេទ ប្រុស អាយុ ៤៥ ឆ្នាំ ជាជនពិការដៃស្តាំម្ខាងដោយសារមីន រស់នៅភូមិជ្រៃថ្មី ឃុំជ្រៃ ស្រុកថ្មគោល ក្រុងបាត់ដំបងបានស្នើសុំ:

-កង់មួយ

-មេគោមួយ

-លុយសំរាប់ពង្រីកមុខរបរចំនួន ៥០០០០រៀល

២. ចន ធី ភេទ ស្រី អាយុ ៤៧ ឆ្នាំ ជាជនពិការជើងឆ្វេងម្ខាងដោយសារមីនរស់នៅភូមិវត្តរការ សង្កាត់អូម៉ាល់ ក្រុងបាត់ដំបង បានស្នើរសុំ:

-កង់មួយ

-ជួសជុលផ្ទះដែលមានទំហំ ៥ x ៦ ម៉ែត្រ

-លុយចំនួន ១០០០០០រៀលសំរាប់ពង្រីកមុខរបរ

៣. អ៊ុំម ជន ភេទ ប្រុស អាយុ ៥៥ឆ្នាំ ជាជនពិការជើងត្រឹមភ្លៅទាំងសងខាងរស់នៅភូមិព្រៃកូនសេក សង្កាត់អូចារ ក្រុងបាត់ដំបងបានស្នើរសុំ:

-ពោះវៀនកងចំនួន ១០

-ពោះវៀនម៉ូតូចំនួន ៥

-សំបកកង់ចំនួន ១០

-សំបកម៉ូតូចំនួន ៥

៤. ជូ នចេក ភេទប្រុស អាយុ ៤៥ ឆ្នាំ ជាជនពិការជើងម្ខាងនិងភ្នែកម្ខាងរស់នៅភូមិវត្តរការ សង្កាត់អូម៉ាល់ក្រុងបាត់ដំបង បានស្នើសុំ:

-មាន់ចំនួន ៣០ក្បាល

-រៀនចាក់វ៉ាក់សាំងមាន់

៥. អ៊ូម សារឿន ភេទប្រុស អាយុ ៣២ ឆ្នាំជាជនពិការជេីងម្ខាងដោយសារមីនរស់នៅភូមិក្បាលខ្មោច ឃុំជ្រៃ ស្រុកថ្មគោល ក្រុងបាត់ដំបង បានស្នើរសុំ:

-សាងសង់ផ្ទះទាំងមូលទំហំ ៥ x ៦ ម៉ែត្រ

៦. ស៊ីម ឈន ភេទ ប្រុស អាយុ ៨៣ ឆ្នាំ ពិការជើងម្ខាងត្រឹមភ្លៅដោយសារមីន រស់នៅភូមិក្បាលខ្មោច ឃុំជ្រៃ ស្រុកថ្មគោល បានស្នើរសុំ:

-ឈើចំនួន កន្លះគីប

-សង្ក័សី ចំនួន ២០ សន្លឹក

៧. ញ៉ែក សុង ភេទ ប្រុស អាយុ ៤៥ ឆ្នាំ ពិការជើងម្ខាងត្រឹមភ្លៅដោយសារមីន រស់នៅភូមិក្បាលខ្មោច ឃុំជ្រៃ ស្រុកថ្មគោល

បានស្នើរសុំ:

-សំភារៈលក់ឥវ៉ាន់ចាប់ហួយជាច្រើនមុខ

៨. ឃុត សឹម ភេទ ប្រុស អាយុ ៤៦ ឆ្នាំ ពិការជើងដោយសារមីន រស់នៅភូមិក្បាលខ្មោច ឃុំព្រៃ ស្រុកថ្មគោលក្រុងបាត់ដំបង បានស្នើរសុំ:

-ពូជពោត ចំនួន ៤០ គីឡូ ក្នុងទំហំដី ចំនួន ២ ហិតា

-ថ្នាំបាញ់សំលាប់ស្មៅចំនួន ២កាដុង

**៤.សកម្មភាពចុះបង្កើតគណៈកម្មកាណ៏អភិវឌ្ឍន៏ជនពិការសហគម៌**

-គ្រោងការណ៏ជួយជនរងគ្រោះដោយសារមីនខេត្តបាត់ដំបងបានបង្កើត គណៈកម្មកាណ៏អភិវឌ្ឍន៏ជនពិការសហគម៏ប្រចាំឃុំព្រៃចំនួន៥ នាក់ដោយមានការទទួលស្គាល់ពីអាជ្ញាធរឃុំ ។ ហើយគណៈកម្មការណ៏នោះមានភារកិច្ចចុះសួសុខទុក និង តំរូវការរបស់ជនពិការ ។ ដូច្នេះដើម្បីលើកទឹកចិត្តដល់ គណៈកម្មកាណ៏អភិវឌ្ឍន៏ជនពិការសហគម៏ គ្រោងការណ៏ជួយជនរងគ្រោះដោយសារមីនខេត្តបាត់ដំបងបានឧបត្ថមប្រាក់ដល់គាត់ចំនួន ៣០ដុល្លាក្នុងមួយខែនិង ចែក កង់ និង សំភារៈធ្វើការដូចជាប៊ិចនិងសៀវភៅជាដើម ។

- ធ្វើការពិនិត្រ និងតាមដានជនពិការ:

ជនពិការដែលបានទទួលសេវាកម្មពីគ្រោងការ សេវាសង្គមជួយជនរងគ្រោះដោយសារគ្រាប់មីន ( SSLS )រួចមក ពួកគាត់ក៏មានទឹកចិត្តសប្បាយរីករាយ ហើយខំប្រឹងប្រែងព្យាយាមយកចិត្តទុកដាក់ប្រកប់មុខរបរដែលបានផ្តល់ជូន ដើម្បីអោយជីវភាពមានការរីកចំរើន និងធូរធា ប្រកបដោយសេចក្តីសុខក្នុងគ្រួសាររបស់គាត់និងដើម្បីកុំអោយ មជ្ឈមណ្ឌលជាតិនៃជនពិការ មានការខកចិត្តនូវអ្វីដែលបានផ្តល់ជូនពួកគាត់ ។

## ៤. សកម្មភាព៦ខែក្រោយ

-បន្តទំនាក់ទំនងជាមួយលោកមេភូមិបន្តទៀត

-ចូលរួមប្រជុំជាមួយឃុំផ្សេងទៀតដើម្បីស្វែងរកជនពិការដោយសាមីន

-ស្វែងរកជនពិការនិងសិក្សាពីតំរូវការរបស់គាត់